ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រដ្ឋបាលខេត្តកណ្តាល

គណៈកម្មាធិការលទ្ធកម្ម

លេខ ៖ ០០៧....សជណ.អល.កណ

# សេចក្តីជូនដំណឹង

## ស្តីពីការងារសាងសង់អគារ ចំនួន៣គម្រោង ជូនសាលាខេត្ត

បានពិនិត្យត្រឹមត្រូវ

អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ

ខេត្តកណ្តាល សូមជូនដំណឹងដល់បណ្តាក្រុមហ៊ុនសំណង់ (គិតទាំងសហគ្រាសឯកត្តបុគ្គល) ទាំងអស់ដែលបានចុះបញ្ជីត្រឹមត្រូវក្នុងព្រះរាជាណាចក្រកម្ពុជាឲ្យបានជ្រាបថាខេត្តកណ្តាលនឹងដាក់ឲ្យដេញថ្លៃជាសាធារណៈដើម្បីជ្រើសរើសអ្នកទទួលការធ្វើការងារសាងសង់អគារ ចំនួន៣គម្រោង ជូន សាលាខេត្ត ៖ ១-សាងសង់អគារសិក្សាអនុវិទ្យាល័យត្រពាំងរកា ទំហំ 9m x 40m នៅឃុំភ្នំបាត ស្រុកពញាឮ , ២-សាងសង់អគារការិយាល័យច្រកចេញចូលតែមួយស្រុកអង្គស្នួលទំហំ 20m x 14m ស្ថិតក្នុងបរិវេណសាលាស្រុកអង្គស្នួល , ៣-សាងសង់អគារការិយាល័យច្រកចេញចូលតែមួយស្រុកកៀនស្វាយ ទំហំ 20m x 14m ស្ថិតក្នុងបរិវេណសាលាស្រុកកៀនស្វាយ ។

ខេត្តកណ្តាលបានរៀបចំឯកសារសម្រាប់ក្រុមហ៊ុនបំពេញ ដើម្បីចូលរួមដេញថ្លៃ និង មានដាក់លក់នៅអង្គភាពលទ្ធកម្មខេត្តកណ្តាលមានអាសយដ្ឋានស្ថិតក្នុងសាលាខេត្តកណ្តាលចាប់ពីថ្ងៃទី៣១...ខែឧសភា.... ឆ្នាំ២០១៨ តទៅនៅរៀងរាល់ម៉ោងធ្វើការ ។

ឯកសារដេញថ្លៃដែលបានបំពេញរួច ត្រូវប្រគល់ជូនអង្គភាពលទ្ធកម្មរដ្ឋបាលខេត្តកណ្តាល យ៉ាងយូរបំផុតត្រឹមថ្ងៃទី០៣..... ខែកក្កដា...ឆ្នាំ២០១៨ វេលាម៉ោង ០៨.......និង.៣០.....នាទី។

ការបើកឯកសារដេញថ្លៃ នឹងប្រព្រឹត្តទៅនៅអង្គភាពលទ្ធកម្មរដ្ឋបាលខេត្តកណ្តាល តាមអាសយដ្ឋានខាងលើ វេលាម៉ោង.០៨....និង.៣០.....នាទី ថ្ងៃទី .០៣..... ខែ កក្កដា... ឆ្នាំ២០១៨ ។

ក្រុមហ៊ុនដែលមានសម្ព័ន្ធភាពជាមួយគ្នា ឬមានប្រភពតែមួយ អាចដាក់ឯកសារដេញថ្លៃបានតែមួយគត់ ។

ក្រុមហ៊ុនដែលមានបំណងចូលរួមដេញថ្លៃ សូមអញ្ជើញទាក់ទងជាមួយអង្គភាពលទ្ធកម្មរដ្ឋបាលខេត្តកណ្តាលដើម្បីទិញឯកសារដេញថ្លៃ និងសាកសួរព័ត៌មាន ដែលទាក់ទងនឹងការដេញថ្លៃនេះ ។

ថ្ងៃ ពុធ..១.រោច...... ខែជេស្ឋ.....ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២

កណ្តាល ថ្ងៃទី.៣០....ខែ.ឧសភា.....ឆ្នាំ ២០១៨

អភិបាល នៃគណៈអភិបាលខេត្ត

និងជាប្រធានគណៈកម្មាធិការលទ្ធកម្ម

ម៉ៅ ភិរុណ

ចម្លងជូន ÷

-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

(អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ)

-អង្គភាពប្រឆាំងអំពើពុករលួយ

-ឯកសារ-កាលប្បវត្តិ